**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងទេសចរណ៍**
**លេខ** ០១៥ សទណ.រពក

CAMBODIA
Kingdom of Wonder
feel the warmth

## សេចក្តីជូនដំណឹង
## ស្តីពី
## ការរៀបចំសន្និបាតបូកសរុបលទ្ធផលការងារវិស័យទេសចរណ៍ឆ្នាំ២០២៥ និងលើកទិសដៅការងារឆ្នាំ២០២៦

ក្រសួងទេសចរណ៍ មានកិត្តិយសសូមជម្រាបជូនដល់សាធារណជន និងសារព័ត៌មានជាតិ-អន្តរជាតិ ឱ្យបានជ្រាបថា ក្រសួងទេសចរណ៍នឹងរៀបចំ **"សន្និបាតបូកសរុបលទ្ធផលការងារវិស័យទេសចរណ៍ឆ្នាំ២០២៥ និងលើកទិសដៅការងារឆ្នាំ២០២៦"** រយៈពេល ២ថ្ងៃ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃអង្គារ-ពុធ ១រោច-២រោច ខែមាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី៣-៤ ខែកុម្ភៈ ឆ្នាំ២០២៦ នៅសណ្ឋាគាររ៉េស៊ីដង់ សុខាភ្នំពេញ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ហួត ហាក់** រដ្ឋមន្ត្រីក្រសួងទេសចរណ៍។

សន្និបាតនេះរៀបចំឡើងក្នុងគោលបំណង តាមដាន ត្រួតពិនិត្យ វាយតម្លៃ និងបូកសរុបលទ្ធផលការងារដែលក្រសួងទេសចរណ៍ និងមហាគ្រួសារវិស័យទេសចរណ៍ សម្រេចបានក្នុងឆ្នាំ២០២៥ និងលើកទិសដៅការងារបន្តឆ្នាំ២០២៦ សំដៅរួមចំណែកអនុវត្តវិធានការគន្លឹះក្នុងការអភិវឌ្ឍវិស័យទេសចរណ៍ ស្របតាមយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ ឱ្យទទួលបានប្រសិទ្ធភាពខ្ពស់ ដើម្បីជាឧត្តមប្រយោជន៍ក្នុងការទ្រទ្រង់កំណើនសេដ្ឋកិច្ច-សង្គម និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋក្រោមអភិក្រម **"ជវភាពនៃប្រព័ន្ធតួអង្គតែមួយ"**។

នៅក្នុងដំណើរការនៃអង្គសន្និបាត **ឯកឧត្តម ហួត ហាក់ រដ្ឋមន្ត្រីក្រសួងទេសចរណ៍** នឹងដឹកនាំពិធីនេះដោយផ្ទាល់ដើម្បីពិនិត្យអំពីវឌ្ឍនភាព វាយតម្លៃលើលទ្ធផលការងារសម្រេចបានក្នុងឆ្នាំ២០២៥ កន្លងទៅ និងលើកឡើងអំពីវិធានការគន្លឹះក្នុងការអភិវឌ្ឍវិស័យទេសចរណ៍ ដោយមានកិច្ចពិភាក្សា ការផ្លាស់ប្តូរមតិយោបល់ និងបទពិសោធ ដើម្បីទទួលបាននូវធាតុចូលថ្មីបន្ថែមក្នុងការគ្រប់គ្រង និងការអភិវឌ្ឍវិស័យទេសចរណ៍ ប្រកបដោយភាពប្រកួតប្រជែង ចីរភាព ភាពធន់ និងបរិយាបន្ន សំដៅជំរុញការអនុវត្តយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ ដើម្បីកំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព ដែលជាគ្រឹះនិងជាមធ្យោបាយដ៏សំខាន់នៃការសម្រេចបានចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០។ អង្គសន្និបាតក៏នឹងមានការដាក់តាំងបង្ហាញពិព័រណ៍សមិទ្ធផលការងាររយៈពេល ១ឆ្នាំក្នុងវិស័យទេសចរណ៍ផងដែរ។

អាស្រ័យហេតុនេះ សូមសាធារណជន និងសារព័ត៌មានជាតិ-អន្តរជាតិ ជ្រាបជាព័ត៌មាន។

ថ្ងៃអង្គារ ១០កើត ខែបុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មករា ឆ្នាំ២០២៦

ក្រសួងទេសចរណ៍

អគារលេខ៣A ផ្លូវលេខ១៦៩ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Website: www.tourism.gov.kh
Telegram: t.me/motgovkh
ទូរស័ព្ទ៖ +៨៥៥ ២៣ ៨៨៥ ៨៩៨
E-mail: admin@tourism.gov.kh